**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួល ឯកឧត្តម ង្វៀន ហ៊ុយតាំង ឯកអគ្គរដ្ឋទូតវៀតណាមថ្មី ប្រចាំនៅកម្ពុជា ចូលជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**ឯកឧត្តម ង្វៀន ហ៊ុយតាំង** (Nguyen Huy Tang) ឯកអគ្គរដ្ឋទូតវៀតណាមថ្មី ប្រចាំនៅកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសម្តែងការស្វាគមន៍ និងអបអរសាទរយ៉ាងកក់ក្តៅចំពោះ **ឯកឧត្តម ង្វៀន ហ៊ុយតាំង** ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៅកម្ពុជា។ **ឯកឧត្តម** បានគូសបញ្ជាក់ថា ជាមួយបទពិសោធន៍នៅកម្ពុជាជាង១០ឆ្នាំ ឯកឧត្តម ឯកអគ្គរដ្ឋទូត ពិតជាបានស្គាល់កម្ពុជាយ៉ាងច្បាស់ ហើយបទពិសោធន៍នេះ នឹងអាចរួមចំណែកដល់ការបំពេញភារកិច្ចរបស់ឯកឧត្តម នៅកម្ពុជា បានជោគជ័យ និងក៏ជាបច្ច័យជំរុញដល់ទំនាក់ទំនងទ្វេភាគីកម្ពុជា និងវៀតណាមកាន់តែល្អប្រសើរឡើងមួយកម្រិតថែមទៀត។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ផងដែរថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួង ត្រៀមផ្តល់កិច្ចសហការ និងការគាំទ្រដល់បេសកកម្មការទូតរបស់ ឯកឧត្តម នៅកម្ពុជា។

**ឯកឧត្តម ង្វៀន ហ៊ុយតាំង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ដែលឆ្លៀតឱកាសទទួលសាវនាការរបស់ ឯកឧត្តម ហើយ ឯកឧត្តម ពិតជាមានក្តីរីករាយជាទីបំផុតដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៅកម្ពុជា។ ឯកឧត្តម ឯកអគ្គរដ្ឋទូត ក៏បានថ្លែងអំណរគុណជាពិសេសផងដែរចំពោះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ដែលក្នុងនាម**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអញ្ជើញថ្លែងសុន្ទរកថាតាមប្រព័ន្ធវីដេអូ ក្នុងពិធីបើកវេទិកាជាន់ខ្ពស់អាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការអនុតំបន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនប្រកបដោយបរិយាប័ន្ន រៀបចំដោយប្រទេសវៀតណាម កាលពីព្រឹកថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២១ នេះ។ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍនៅលើគ្រប់វិស័យយ៉ាងឆាប់រហ័ស ក្រោមព្រះរាជតំរិះដឹកនាំរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ជាពិសេសវឌ្ឍនភាព នៅ២ឆ្នាំចុងក្រោយដែលកម្ពុជាបានដាក់ចេញ និងអនុវត្តគោលនយោបាយ និងកម្មវិធីចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋ

របស់ខ្លួន និងជនបរទេសដែលរស់នៅនិងបំពេញការងារលើទឹកដីកម្ពុជា ប្រកបដោយជោគជ័យបំផុត ដែលជាសញ្ញាមួយដ៏ល្អថា កម្ពុជាអាចបើកប្រទេសឡើងវិញនៅគ្រប់វិស័យ ជាពិសេសទេសចរណ៍។

ឯកឧត្តម ឯកអគ្គរដ្ឋទូត បានបង្ហាញនូវចំណាប់អារម្មណ៍ថា កម្ពុជា និងវៀតណាម មានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីកាន់តែល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយឯកឧត្តម នឹងខិតខំធ្វើយ៉ាងណាឱ្យទំនាក់ទំនងជាប្រពៃណី សាមគ្គីភាព និងភាពជាអ្នកជិតខាងល្អនៅតែល្អប្រសើរតរហូត។

ដើម្បីអបអរសាទរខួបលើកទី៥៥ នៃទំនាក់ទំនងការទូតកម្ពុជា និងវៀតណាម នៅឆ្នាំ ២០២២ ខាងមុខនេះ ភាគីទាំងពីរបានឯកភាពលើសកម្មភាពរួមគ្នាមួយចំនួន រួមមាន ការរៀបចំបង្ហាញវប្បធម៌រវាងប្រទេសទាំងពីរ និងការពង្រីកការផ្សព្វផ្សាយអប់រំ ដើម្បីឱ្យប្រជាជន ជាពិសេសយុវជនជំនាន់ក្រោយមានការយល់ដឹងឱ្យបានទូលំទូលាយអំពីប្រវត្តិសាស្ត្រនៃការជួយគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរ។

ភាគីទាំងពីរ ឯកភាពសហការបន្តពង្រឹងនិងពង្រីកទំនាក់ទំនងជាប្រពៃណីនិងកិច្ចសហប្រតិបត្តិការគ្រប់វិស័យ អោយកាន់តែមានប្រសិទ្ធភាព ស៊ីជម្រៅ និងមានវិសាលភាពកាន់តែទូលំទូលាយ តាមរយៈការប្តេជ្ញាចិត្តរបស់ភាគីទាំងពីរ អនុវត្តអោយបានខ្ជាប់ខ្ជួននូវសេចក្តីសម្រេចចិត្តរបស់ថ្នាក់ដឹកនាំទាំងពីរ និងកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការដែលមាន ឈរលើស្មារតីមិត្តភាពសាមគ្គីភាព ភាពជាបងប្អូនដែលតែងជួយគ្នាទៅវិញទៅមក ការយោគយល់និងជឿទុកចិត្តគ្នា និងវិបុលភាពរួម។

ក្នុងនេះផងដែរ ភាគីទាំងពីរ ក៏បានឯកភាពគ្នាជំរុញទៅភាគីពាក់ព័ន្ធរៀងៗខ្លួនឱ្យឆាប់បញ្ចប់ការងារការបោះបង្គោលព្រំដែនគោកដែលនៅសេសសល់ប្រមាណ១៦% ឱ្យបានឆាប់រហ័សផងដែរ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូន ឯកឧត្តម ឯកអគ្គរដ្ឋទូត ផងដែរអំពីអាទិភាពនានា របស់កម្ពុជា ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២ ហើយ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានអះអាងជាថ្មីអំពីការគាំទ្ររបស់វៀតណាមចំពោះការធ្វើជាប្រធានអាស៊ានរបស់កម្ពុជាឱ្យទទួលបានជោគជ័យ។

ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរយោបល់គ្នាផងដែរលើបញ្ហាតំបន់ និងអន្តរជាតិដែលជាចំណាប់អារម្មណ៍រួម និងផលប្រយោជន៍ទៅវិញទៅមកផងដែរ។

ជាទីបញ្ចប់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជូនពរឯកឧត្តម **វ៉ៀន ហ៊ុយតាំង** ឲ្យទទួលបាននូវភាពជោគជ័យក្នុងអាណត្តិបេសកកម្មការទូតនៅក្នុងប្រទេសកម្ពុជា៕

---------------